**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៥៤ សសរ**

# សេចក្តីសម្រេច
# ស្តីពី
# ការរៀបចំក្រុមការងារកម្ពុជា
# ប្រឆាំងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៦/០០៤ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- បានឃើញសេចក្តីសម្រេចលេខ ៧១ សសរ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការរៀបចំក្រុមការងារកម្ពុជាប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

## សម្រេច

**ប្រការ ១.-**

ត្រូវបានរៀបចំក្រុមការងារកម្ពុជាប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ ហៅកាត់ថា ក្រុមការងារខមមីត កម្ពុជា (Cambodian COMMIT Taskforce) ដែលមានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- លោកជំទាវ | **សាន្ត អរុណា** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ប្រធាន |
| ២- ឯកឧត្តម | **ហោ សារុន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣- លោកជំទាវ | **ចន្ទ័ ហាវ៉ានថង្គី** | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៤- លោកជំទាវ | **ជួញ សុផៃ** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥- លោកជំទាវ | **ម៉ិន ពុទ្ធី** | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | អនុប្រធាន |
| ៦- លោកជំទាវ | **មាសសាឯម ដានី** | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិកា |
| ៧- លោកជំទាវ | **ហោខ ស៊ីផុន** | ទីប្រឹក្សាក្រសួងកិច្ចការនារី | សមាជិកាអចិន្ត្រៃយ៍ |
| ៨- លោកជំទាវ | **ជា ផល្លីន** | ទីប្រឹក្សាក្រសួងព័ត៌មាន | សមាជិកា |
| ៩- លោកជំទាវ | **ម៉ែន សុមេធា** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ | សមាជិកា |
| ១០-ឯកឧត្តម | **សេខ សក្ដា** | អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | សមាជិក |
| ១១-ឯ.ឧ.ឧត្តមសេនីយ៍ឯក | **ប៉ុល ភិធេយ្យ** | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន ក្រសួងមហាផ្ទៃ | សមាជិក |
| ១២-លោក | **តាន់ សេណារ៉ុខ** | ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | សមាជិក |
| ១៣-លោកវេជ្ជ. | **ទស់ សីលវ៉ាត់** | អគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | សមាជិក |
| ១៤-លោក | **ម៉េខ ហៀខ** | ប្រធាននាយកដ្ឋានការងារកុមារ ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | សមាជិក |
| ១៥-លោក | **ថូ សំណាខ** | អនុប្រធាននាយកដ្ឋានច្បាប់និងកុងស៊ុល ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៦-លោកស្រី | **ពុត និសវ្ល័យ** | អនុប្រធាននាយកដ្ឋានក្រសួងអប់រំ យុវជន និងកីឡា | សមាជិកា |
| ១៧-លោកវរសេនីយ៍ទោ | **សឿ ដារ៉ា** | នាយការិយាល័យបទល្មើសជួញដូរមនុស្សនៃស្នងការដ្ឋានយុត្តិធម៌ កងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៨-តំណាងយុវជន០២រូប | | | សមាជិក។ |

**ប្រការ ២.-**

ក្រុមការងារខមមីតកម្ពុជា មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រុមការងាររបស់ក្រសួង-ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលពាក់ពន្ធ័នឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- សហការជាមួយប្រទេសជាសមាជិក ខមមីត នៅក្នុងមហាអនុតំបន់មេគង្គនិងក្នុងតំបន់ ឱ្យបានសកម្មនិងមានប្រសិទ្ធភាព
- សហការជាមួយគម្រោងសកម្មភាពអង្គការសហប្រជាជាតិ ដើម្បីធ្វើសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស ហៅកាត់ថា UN-ACT ប្រចាំកម្ពុជា ថ្នាក់តំបន់ប្រចាំទីក្រុងបាងកក និងអង្គការជាតិ-អន្តរជាតិ រួមជាមួយបណ្តាដៃគូអភិវឌ្ឍន៍ដទៃទៀត ក្នុងការសម្របសម្រួលរាល់សកម្មភាពថ្នាក់ជាតិ និងថ្នាក់តំបន់ដែលពាក់ព័ន្ធនឹងបញ្ហាជួញដូរមនុស្ស
- រៀបចំផែនការសកម្មភាព ខមមីត កម្ពុជា និងផែនការថ្នាក់មហាអនុតំបន់មេគង្គ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស
- ចូលរួមរៀបចំផែនការសកម្មភាពជាតិស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- រៀបចំវគ្គបណ្តុះបណ្តាលអភិវឌ្ឍន៍ធនធានមនុស្សស្តីពី យុទ្ធសាស្ត្រប្រឆាំងនឹងអំពើជួញដូរមនុស្សនិងជួយជនរងគ្រោះ
- ធ្វើការសិក្សាស្រាវជ្រាវ ផ្សព្វផ្សាយចែកចាយឯកសារនានាពាក់ពន្ធ័អំពើជួញដូរមនុស្សនិងជួយជនរងគ្រោះ
- រៀបចំនិងជំរុញអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ឬកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគីស្តីពី កិច្ចសហប្រតិបត្តិការប្រឆាំងនឹងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គនិងថ្នាក់តំបន់ ប្រកបដោយប្រសិទ្ធភាព
- ពង្រីកកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន និងដៃគូអភិវឌ្ឍនានា រៀបចំធ្វើរបាយការណ៍សកម្មភាពប្រចាំឆ្នាំរបស់ ខមមីត កម្ពុជា និងលើកទិសដៅសម្រាប់អនុវត្តបន្តស្តីពីការងារប្រឆាំងអំពើជួញដូរមនុស្សជូនរាជរដ្ឋាភិបាល
- ពិនិត្យតាមដានឡើងវិញរៀងរាល់៣ឆ្នាំម្តង នូវការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ឬកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគីស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល
- ចូលរួមកិច្ចប្រជុំថ្នាក់អន្តរជាតិនិងតំបន់ តាមការអញ្ជើញរបស់ដៃគូពាក់ព័ន្ធ និងការចាត់តាំងរបស់រាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

**ប្រការ ៣.-**

ប្រធានក្រុមការងារ ខមមីត កម្ពុជា ត្រូវលើកគម្រោងថវិកាសម្រាប់កិច្ចប្រជុំ និងការងាររួមសម្រាប់ការងារ ខមមីត កម្ពុជា ដាក់បញ្ចូលក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងជាប្រធានក្រុមការងារ។ ដោយឡែក អនុប្រធាន សមាជិក ក្រុមការងារ ខមមីត កម្ពុជា នៅតាមបណ្តាក្រសួង ស្ថាប័ន ត្រូវលើកគម្រោងថវិកាចំណាយសម្រាប់សកម្មភាពការងារជំនាញពាក់ព័ន្ធនឹងការងារ ខមមីត កម្ពុជា បញ្ចូលក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសាមី។

ក្រុមការងារនេះមានសិទ្ធិស្នើសុំ ទទួល និងគ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងប្រភពផ្សេងៗទៀត សម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

**ប្រការ ៤.-**

ក្រុមការងារ ខមមីត កម្ពុជា មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកិច្ចការនារី។

ក្រុមការងារ ខមមីត កម្ពុជា មានលេខាធិការដ្ឋានអចិន្ត្រៃយ៍ ស្ថិតនៅក្រោមក្រសួងកិច្ចការនារី។ លេខាធិការដ្ឋានអចិន្ត្រៃយ៍នេះ មានប្រធានមួយរូប អនុប្រធាន និងមន្ត្រីមួយចំនួន ជាជំនួយ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមការងារ ខមមីត កម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី។

**ប្រការ ៥.-**

សមាជិកក្រុមការងារ ខមមីត កម្ពុជា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ប្រធានក្រុមការងារមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធចូលរួមប្រជុំ។

**ប្រការ ៦.-**

សេចក្តីសម្រេចលេខ ៧១ សសរ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការរៀបចំក្រុមការងារកម្ពុជាប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេច នេះត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

ក្រសួងព្រះបរមរាជវាំង

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ